ស អ ស ជ

REDA

# សមាគមអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

## Rural Economic Development Association

ផ្លូវជាតិលេខ ១ ភូមិព្នៅ ឃុំតាសួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង

ប្រអប់សំបុត្រ ៣០៣ស៊ីស៊ីស៊ី ភ្នំពេញ ទូរស័ព្ទ : ០១២ ៩៤០ ៧៥៥/០១១ ៩៤០ ៧៥៥

E-mail: redakhorg@yahoo.com/redakhorg@gmail.com

# សំរង់

ឈ្មោះគំរោង (Title)

សហគមន៏ផ្លាស់ប្តូរឥរិយាបទចូលរួមគាំទ្រនិងថែរក្សាកុមារកំពុងរស់នៅជាមួយមេរោគអេដស៏កុមារទទួលផលប៉ះពាល់ពីមេរោគអេដស៏និងកុមារងាយរងគ្រោះ ដើម្បីអភិវឌ្ឍន៏អោយមាននិរន្តរភាពរស់នៅក្នុងភូមិស្រុកដូចគេដូចឯង ។

# ការណែនាំ/ប្រវត្តិ/បញ្ហា Introduction/Background/Issues

ខេត្តស្វាយរៀងជាខេត្តដែលដីពុំសូវមានជីជាតិហើយច្រើនតែជួបប្រទះភាពរាំងស្ងួត ទឹកជំនន់ដែលជាហេតុបង្កអោយមានការចំណាកស្រុកដែលនាំមកនូវជំងឺអេដស៍បានឆ្លងរាលដាលដល់ប្រពន្ធកូននិងស្ត្រីបំរើការកំសាន្តសប្បាយ ។កត្តានេះហើយដែលបង្កអោយមានចំនួនកុមារកំព្រារកាន់តែច្រើនឡើងជាលំដាប់ ។

កុមារទាំងបីប្រភេទខាងលើនេះកំពុងតែទទួលផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសហគមន៍ ញាតិសន្តាន អ្នកជិតខាងបានរំលោភកេងប្រវ័ញ្ចទ្រព្យសម្បត្តិទាំងអចលននិងចលនវត្ថុដោយពុំមានការពិចារណាលើផលប៉ះពាល់ដល់គុណភាពជីវិតរបស់កុមារទាំងនោះឡើយ ។

កុមារដែលត្រូវបានអណាព្យាបាលកេងប្រវ័ញ្ចពលកម្មកុមារដោយពួកគេពុំមានពេលលំហែរនិងគ្មានឱកាសរៀនសូត្រ គ្រប់គ្រាន់ ។ ចំពោះកុមារដែលបានរស់នៅជាមួយយាយតាចាស់ៗពុំមានឱកាសរៀនសូត្រទាល់តែសោះដោយពួកគេជាប់រវល់ជួយកិច្ចការសព្វបែបយ៉ាងនៅក្នុងគ្រួសារ ។

បញ្ហាដែលធ្ងន់ធ្ងរបំផុតនោះគឺកុមារីដែលស្ថិតនៅក្នុងកុមារទាំងបីក្រុមដែលមានរូបរាងស្អាតត្រូវបានឈ្មួញជួញដូរផ្លូវភេទសំដីផ្អែម ប្រើទឹកប្រាក់ទាក់ទាញទឹកចិត្តអ្នកអនាព្យាបាលអោយទៅធ្វើការទីនេះទីនោះតែទីបំផុតកុមារីទាំងនោះបានក្លាយខ្លួនទៅជាស្ត្រីបំរើការកំសាន្តសប្បាយដែលកំពុងតែប្រឈមមុខជាមួយមេរោគអេដស៍ ។

# ការពិពណ៌នាពីគំរោង Discription

ដើម្បីទប់ទល់និងដោះស្រាយបញ្ហាដែលកំពុងប្រឈមមុខនៅតាមសហគមន៍ទើបក្រុមការងារអង្គការ REDA ពិភាក្សាជាមួយក្រុមប្រឹក្សាភិបាលដើម្បីបង្កើតគំរោងថែទាំបង្ការនិងធ្វើបណ្តាំមរតកដើម្បីបំពេញតំរូវការរបស់សហគមន៍ជាពិសេសកុមារងាយរងគ្រោះក្នុងបំណងអោយពួកគេរួចផុតពីការកេងប្រវ័ញ្ចទ្រព្យសម្បត្តិ ពលកម្ម និងផ្លូវភេទរបស់កុមារ ។ ដែលទទួលបានមូលនិធិឧបត្ថម្ភដោយអង្គការ KHANA និង Pact Cambodia ។

ដើម្បីអោយគំរោងការនេះប្រព្រឹត្តបានប្រកបដោយជោគជ័យ REDA បានបង្កើតក្រុមការងារដូចខាងក្រោមនេះ

-គណៈកម្មាធិការគ្រប់គ្រងកុមារថ្នាក់ស្រុក ។

-អនុគណៈកម្មការគ្រប់គ្រងកុមារថ្នាក់ឃុំ ។

-បណ្តាញអ្នកស្ម័គ្រចិត្តតាមឃុំ ។

-គណៈកម្មការគ្រប់គ្រងហឹបសង្គ្រោះ ។

-អ្នកស្ម័គ្រចិត្តតាមភូមិ ។

ដើម្បីអោយគំរោងការនេះកាន់តែមានដំណើការរលូនទៅមុខបានប្រកបដោយផ្លែផ្កានោះ REDA  បានបង្កើតសកម្មភាពដូចតទៅនេះ

-ធ្វើបណ្តុំមរតក, សៀវភៅចងចាំ, ផែនការអនាគតនៅក្នុងតំបន់គោលដៅ ។

-បង្កើតទិវាកុមាររីករាយ, កុមារសប្បាយសប្បាយ ។

-បង្កើតទិវាសហគមន៏នៅក្នុងតំបន់គោដៅ ។

-ពិនិត្យហឹបសង្គ្រោះ, ការរាប់លុយ, ការចែកចាយ, ហឹបសង្គ្រោះមានចលនា ។

-ប្រជុំជាមួយគណៈកម្មាធិការគ្រប់គ្រងកុមារថ្នាក់ស្រុក ។

-ប្រជុំជាមួយអនុគណៈកម្មការគ្រប់គ្រងកុមារថ្នាក់ឃុំ ។

-ប្រជុំជាមួយបណ្តាញអ្នកស្ម័គ្រចិត្តតាមឃុំនិងភូមិ ។

# លទ្ធផល Results

អ្នករស់នៅជាមួយមេរោគអេដស៏មានភាពរីករាយនិងមានទំនោរធ្វើបណ្តាំមរតក សៀវភៅចងចាំនិងផែនការអនាគតទុកអោយទាយាទរបស់ពួកគេ ដោយគេលែងបារម្ភពីការបាត់បង់ទ្រព្យសម្បត្តិទោះជាពួកគេបាត់បង់ជីវិតក៏ដោយ ។ REDA បានធ្វើបណ្តាំមរតកចំនួន១៤២គ្រួសារ សៀវភៅចងចាំចំនួន៩៥គ្រួសារ ផែនការអនាគត៣៤២គ្រួសារ ។

អជ្ញាធរមូលដ្ឋានភូមិ ឃុំ ស្រុក បានចូលរួមយ៉ាងសកម្មក្នុងការជ្រោមជ្រែងពន្យល់ដល់អ្នករស់នៅជាមួយមេរោគអេដស៏អោយចូលរួមធ្វើបណ្តាំមរតកនិងផែនការអនាគតកូនៗរបស់ពួកគេ ។ អជ្ញាធរមូលដ្ឋានភូមិ នគរបាលប៉ុស្តិ៍ ឃុំ ស្រុក បានឃ្លាំមើល រាយការណ៍ និងចាត់វិធានការចំពោះការប្រព្រឹត្តខុសឆ្គងរបស់ឪពុកម្តាយនិងអ្នកអនាព្យាបាលមកលើកុមារ មិនត្រឹមតែប៉ុណ្ណោះពួកគាត់ជំរុញអោយហ៊ឺបសង្គ្រោះមានចលនា ។

# មេរៀនដែលទទួលបានពីការរៀនសូត្រ Lesson Learned

តាមការអះអាងរបស់មន្ត្រីនគរបាលនិងមេឃុំបានបញ្ជាក់ថា៖ ក្រោយពីអង្គការ REDA បានធ្វើបណ្តុំមរតកដល់ក្រុមជនដែលរងគ្រោះដោយជំងឺអេដស៍រួចមក បញ្ហាទំនាស់ដីធ្លីត្រូវបានកាត់បន្ថយមួយចំនួនធំ ។

អ្នករស់នៅជាមួយមេរោគអេដស៍អស់កង្វល់ពីការបាត់បង់ទ្រព្យសម្បត្តិហើយការមាក់ងាយនិងការរើសអើងបានប្រែក្លាយទៅជាការគាំទ្រចំពោះអ្នករស់នៅជាមួយមេរោគអេដស៍នៅក្នុងសហគមន៍ ។

អ្នករស់នៅជាមួយមេរោគអេដស៍សព្វថ្ងៃនេះត្រូវបានគេអញ្ជើញចូលរួមក្នុងពិធីបុណ្យទានផ្សេងៗនៅក្នុងសហគមន៍រស់នៅរបស់ពួកគេ ។

# អនុសាសន៍ Recomandation

ស្នើសុំអោយម្ចាស់ជំនួយបន្តរមូលនិធិសំរាប់កម្មវិធីនេះតទៅទៀត ព្រោះវាមានសារៈប្រយោជន៏ខ្លាំងណាស់ដល់ក្រុមជនដែលកំពុងរស់នៅជាមួយនិងមេរោគអេដស៏ និងជាហេតុធ្វើអោយសហគមន៏មានការគាំទ្រដល់កុមារទាំង៣ប្រភេទ ។

## អសយដ្ឋានទំនាក់ទំនង:


លោក ស៊ឹម កល្យាណ នាយកប្រតិបត្តិអង្គការ REDA

ទូរស័ព្ទ : ០១២ ៩៤០ ៧៥៥, ០១១ ៩៤០ ៧៥៥

អ៊ីមែល : redakhorg@gmail.com/ redakhorg@yahoo.com

សូមអរគុណចំពោះការចូលរួមយកចិត្ត

ទុកដាក់ស្តាប់របស់អស់លោកលោកស្រី !